ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងមុខងារសាធារណៈ

# សាររំលែកទុក្ខ

**ជូនចំពោះ**

**លោកជំទាវ នាង លីណា ទីប្រឹក្សាក្រសួងមុខងារសាធារណៈ និងក្រុមគ្រួសារ**

ខ្ញុំ និងថ្នាក់ដឹកនាំ ព្រមទាំងមន្ត្រីរាជការ នៃក្រសួងមុខងារសាធារណៈទាំងអស់មានក្តីរន្ធត់ និងសោកស្តាយជាពន់ពេក ដោយបានទទួលដំណឹងថា **ឧបាសក នាង មិន** ដែលត្រូវជាលោកឪពុករបស់ **លោកជំទាវ នាង លីណា** បានទទួលមរណភាព កាលពីថ្ងៃពុធ ១២រោច ខែបុស្ស ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦ ត្រូវនឹងថ្ងៃទី១៨ ខែមករា ឆ្នាំ២០២៣ វេលាម៉ោង១០:៥០នាទីព្រឹក ក្នុងជន្មាយុ ៩១ឆ្នាំ ដោយជរាពាធ។

ក្នុងឱកាសប្រកបដោយក្តីរំជួលចិត្ត និងសមានទុក្ខដ៏ក្រៀមក្រំនេះ ខ្ញុំ និងថ្នាក់ដឹកនាំ ព្រមទាំងមន្ត្រីរាជការ នៃក្រសួងមុខងារសាធារណៈទាំងអស់ សូមចូលរួមសម្តែងនូវមរណទុក្ខដ៏ក្រៀមក្រំ និងសោកស្តាយជាទីបំផុតជាមួយ **លោកជំទាវ នាង លីណា និងក្រុមគ្រួសារ** ចំពោះការបាត់បង់ដ៏ធំធេងមិនអាចរកអ្វីមកប្រៀបបានមួយនេះ។

ខ្ញុំសូមឧទ្ទិសបួងសួងជូនដួងវិញ្ញាណក្ខន្ធ **ឧបាសក នាង មិន** បានអញ្ជើញទៅកាន់សុគតិភពកុំបីឃ្លៀងឃ្លាតឡើយ។

សូម **លោកជំទាវ នាង លីណា និងក្រុមគ្រួសារ** ទទួលនូវការរំលែកទុក្ខដ៏ក្រៀមក្រំបំផុតពីយើងខ្ញុំ។

ថ្ងៃពុធ ១២រោច ខែបុស្ស ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦
រាជធានីភ្នំពេញ ថ្ងៃទី១៨ ខែមករា ឆ្នាំ២០២៣

**តំណាងថ្នាក់ដឹកនាំនិងមន្ត្រីរាជការនៃក្រសួងមុខងារសាធារណៈ**

**រដ្ឋមន្ត្រី**

**ព្រុំ សុខា**